ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សាលាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខៈ ៨៤៨
ចុះថ្ងៃទី ០៣-១០-២០១១
សាលដីកា
លេខ ៖ ៥១ "ក្រ.III.ស"
ចុះថ្ងៃទី ១២-០៧-២០១៣

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

៤៤៤ ★ ៣៣៣

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១៣ ដោយមានសមាសភាពដូចខាងក្រោមៈ

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted]

**<u>ក្រឡាបញ្ជី</u>**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៨៤៨ ចុះថ្ងៃទី ០៣ ខែតុលា ឆ្នាំ២០១១ ដែលមានៈ

- ជនជាប់ចោទឈ្មោះ [redacted]ផល ភេទប្រុស អាយុ ៤០ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ កើតនៅភូមិអូរវាយ ឃុំស្ពឺ ស្រុកចំការលើ ខេត្តកំពង់ចាម ទីលំនៅសព្វថ្ងៃភូមិ[redacted] ស្រុកជុំគីរី ខេត្តកំពត ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ[redacted](រ) ប្រពន្ធឈ្មោះ [redacted] មានកូន ៣នាក់ ទោសគ្មានពីមុន ឃុំខ្លួនថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០១០។

មានលោកស្រី [redacted]សីភក្តិ ជាមេធាវីការពារ។

<u>ជាប់ចោទពីបទ:</u> ប្លន់ (លួចមានគ្នាច្រើន) ប្រព្រឹត្តនៅភូមិតាកុល ឃុំស្នាយអញ្ជិត ស្រុកជុំគីរី ខេត្តកំពត កាលពីថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភារៈ ភេទប្រុស ទីលំនៅសព្វថ្ងៃភូមិតាកុល ឃុំស្នាយអញ្ជិត ស្រុកជុំគីរី ខេត្តកំពត។ ៚

## ដំណើររឿងមានដូចតទៅ

កាលពីថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៩ ម៉ោងប្រហែល ០១រំលងអាធ្រាត្រ មានអំពើប្លន់ (លួចមានគ្នាច្រើន) បានកើតឡើងនៅភូមិតាកុល ឃុំស្នាយអញ្ជិត ស្រុកជុំគីរី ខេត្តកំពត ដែលអំពើខាងលើបង្កដោយឈ្មោះ [redacted] ឌុក ភេទប្រុស អាយុ ៤៥ឆ្នាំ និងឈ្មោះ [redacted] ផល ភេទប្រុស អាយុ ៤៥ឆ្នាំ ដោយជនសង្ស័យទាំងពីរនាក់បាននាំគ្នាចូលទៅស្រាយរបងចូលយកគោចំនួនពីរក្បាលរបស់ឈ្មោះ [redacted] ភារៈ ភេទប្រុស អាយុ ២១ឆ្នាំ នៅចំណុចភូមិតាកុល ឃុំស្នាយអញ្ជិត ស្រុកជុំគីរី ខេត្តកំពត ដែលម្ចាស់គោបានចងទុកនៅក្រោមផ្ទះ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៤៣ ឃ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកំពត ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ

១- ផ្ដន្ទាទោស

លើឈ្មោះ [redacted] ផល ភេទប្រុស អាយុ ៤០ឆ្នាំ និងឈ្មោះ [redacted] ឌុក ភេទប្រុស អាយុ ៤៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗចំនួន ០៤(បួន)ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន ពីបទ លួចដោយមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិតាកុល ឃុំស្នាយអញ្ជិត ស្រុកជុំគីរី ខេត្តកំពត កាលពីថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២- បង្គាប់ឲ្យឈ្មោះ [redacted] ផល និងឈ្មោះ [redacted] ឌុក រួមគ្នាសងសំណងជម្ងឺចិត្តចំនួន ៥.០០០.០០០ (ប្រាំលាន)រៀល ទៅឲ្យឈ្មោះ [redacted] ភារៈ ជាដើមបណ្ដឹងរដ្ឋប្បវេណី គិតពីថ្ងៃសាលក្រមចូលជាស្ថាពរ។

៣- បង្គាប់ឲ្យធ្វើការចាប់ខ្លួន ឃុំខ្លួនលើឈ្មោះ [redacted] ឌុក ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០១១ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ផល និងចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី, កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ឌុក បើកសិទ្ធិប្ដឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់។

- បានឃើញ សេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍លេខ ៦៧ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ផល ជាជនជាប់ចោទ សុំប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៣ ឃ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកំពត ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ក្រឡាបញ្ជីអានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភារៈ បានឆ្លើយនៅសាលាដំបូងខេត្តកំពត។

ជនជាប់ចោទឈ្មោះ [redacted] ផល ឆ្លើយថា៖ ខ្លួនប្ដឹងឧទ្ធរណ៍ ព្រោះខ្លួនអត់បានយកទេ នៅថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៩ មិត្តភក្តិខ្លួនបានហៅខ្លួនពីល្ងាចទៅធ្វើសំណង់នៅស្រែអំបិល នៅថ្ងៃទី ១៣ នេះខ្លួនបានជិះរ៉ឺម៉កពីជុំគីរី ទៅផ្សារឈូក ចេញទៅម៉ោង ៨ជាងព្រឹក យប់ថ្ងៃទី ១២ ខ្លួននៅផ្ទះមែន នៅព្រឹកថ្ងៃទី ១៣ ខ្លួនអត់បានគេចខ្លួនទេ ខ្លួនអត់បានឃើញឈ្មោះ ឌូក ក៏មិនបាននិយាយជាមួយឈ្មោះ ឌូក ទេ។ ខ្លួនបានប្រើកូនខ្លួនឲ្យទៅទារលុយពីឈ្មោះ [redacted] ភារៈ មែន លើកទី ១ អត់បាន លើកទី ២ ខ្លួនឲ្យកូនទៅទារម្ដងទៀត ហើយខ្លួនអត់បានទៅកាត់ខ្សែគោឈ្មោះ [redacted] ភារៈ ទេ, ខ្លួនបានចេញទៅធ្វើសំណង់នៅស្រែអំបិលបានមួយរយៈ ខ្លួនមកធ្វើនៅភ្នំពេញ ខ្លួនបានទៅមកៗ លុះខ្លួនបានមកពីកំពង់សោមបាន ៤ ទៅ ៥ថ្ងៃ ហើយពូ ថុល ហៅមកជួយធ្វើការ ក៏ត្រូវគេចាប់ខ្លួនទៅ ខ្លួនជាប់ពន្ធនាគារចំនួន ២ឆ្នាំកន្លះ ហើយខ្លួនស្គាល់ឈ្មោះ [redacted] ភារៈ តែខ្លួនមិនបានលួចគោគេទេ ឈ្មោះ [redacted] ឌូក ខ្លួនស្គាល់នៅក្នុងគុក។ សំណូមពរ សុំបន្ធូរបន្ថយទោសឲ្យខ្លួនផង។

## សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានពិនិត្យ និងពិចារណាលើអង្គហេតុ មហាអយ្យការឃើញថា តាមការស្រាវជ្រាវរបស់សមត្ថកិច្ច និងចម្លើយសាក្សី ក៏ដូចជា ដើមបណ្ដឹងរដ្ឋប្បវេណីឃើញថា គ្រាន់តែសង្ស័យលើឈ្មោះ [redacted] ផល និងឈ្មោះ [redacted] ឌូក ពុំឃើញមានភស្តុតាងគ្រប់គ្រាន់ឡើយ។ មានតែចម្លើយសាក្សីឈ្មោះ [redacted] សារិទ្ធ ចុះថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០០៩ ចំពោះមុខនគរបាលថា បានឃើញជនពីរនាក់មិនស្គាល់ឈ្មោះដឹកគោម្នាក់មួយក្បាល ម្នាក់ពាក់អាវស ម្នាក់ពាក់អាវខ្មៅ ដូចការអះអាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីបានឃើញដែរ។ ដូចនេះ គប្បីកោះសាក្សី និងដើមបណ្ដឹងមកសួរដេញដោលចំពោះមុខសវនាការឲ្យបានច្បាស់លាស់ និងសុំឲ្យក្រុមប្រឹក្សាពិចារណាឡើងវិញ ដោយអង្គហេតុពុំឃើញមានភស្តុតាងច្បាស់លាស់។ ដូច្នេះ សុំក្រុមប្រឹក្សាពិចារណាតាមច្បាប់។

## សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

កូនក្ដីខ្លួនបានបញ្ជាក់ថា មិនបានលួចគោគេទេ ឈ្មោះ [redacted] ភារៈ ចោទក៏គ្មានសាក្សីបានឃើញផ្ទាល់ដែរ ហើយសាក្សីគ្រាន់តែថា វាមានមនុស្សពីរនាក់ដឹកគោទៅផ្សារឈូក តែមិនដឹងនរណាទេ គ្រាន់តែឃើញកូនក្ដីខ្លួននៅផ្សារឈូក ហើយកូនក្ដីខ្លួនធ្លាប់មានទំនាស់ជាមួយគ្នា ស្រាប់តែសង្ស័យលើកូនក្ដីខ្លួន រឿងនេះមិនមានសាក្សី ភស្តុតាងដាក់បន្ទុកលើកូនក្ដីខ្លួនទេ កូនក្ដីខ្លួនបានជាប់ពន្ធនាគារ ២ឆ្នាំ ជាងហើយ សូមបដិសេធចោលសាលក្រមព្រហ្មទណ្ឌលេខ ៤៣ ឃ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកំពត និងសុំដោះលែងកូនក្ដីខ្លួនឲ្យមានសេរីភាព។

- ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្ដាប់អំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់។

## សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថាៈ

១- បណ្តឹងឧទ្ធរណ៍លេខ ៦៧ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ផល ជាជនជាប់ចោទ ធ្វើក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- តាមចម្លើយជនជាប់ចោទថា ខ្លួនមិនបានលួចយកគោរបស់ឈ្មោះ [redacted] ភារៈ ជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ កាលពីថ្ងៃកើតហេតុខ្លួននៅធ្វើការសំណង់នៅស្រែអំបិល។ ខ្លួនមិនស្គាល់ឈ្មោះ [redacted] ឌូក នោះទេ,

៣- តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីថា កាលពីថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៩ វេលាម៉ោង ៦ល្ងាច ខ្លួនឃើញឈ្មោះ ឌូក និងឈ្មោះ [redacted] ផល ឈរនិយាយគ្នានៅខាងត្បូងស្ពាន មួយសន្ទុះក៏បែកគ្នា។ នៅយប់នោះខ្លួនទៅដេកនៅផ្ទះឪក្មេក ឯភូមិត្រពាំងស្គន់ លុះព្រឹកឡើងវេលាម៉ោង ៦ ត្រឡប់មកផ្ទះវិញ បាត់គោ ខ្លួនក៏សង្ស័យថា ឈ្មោះ [redacted] ឌូក និងឈ្មោះ [redacted] ផល ជាអ្នកលួច។

៤- តាមចម្លើយសាក្សីឈ្មោះ [redacted] សារិទ្ធ ថា ខ្លួនឃើញមនុស្ស ០២នាក់ ដឹកគោមួយម្នាក់ៗ នៅវេលាម៉ោងប្រហែល ០២យប់។

- ឈ្មោះ [redacted] ស៊ូ ថា កាលពីថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៩ វេលាម៉ោង ៥ល្ងាច មានមនុស្សប្រុសម្នាក់មិនមែនឈ្មោះ ឌូក ទេ សួរខ្លួនរកឈ្មោះ ផល ដោយថាជាគូកន,

- សាក្សីឈ្មោះ [redacted] អ៊ួច ថា ឈ្មោះ ឌូក ធ្វើការចាក់លូជាមួយខ្លួន ១០ថ្ងៃហើយ, នៅថ្ងៃទី ១៤ ខែឧសភា ឆ្នាំ២០០៩ និងថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០០៩ បាត់មិនឃើញទៅធ្វើការទេ។

៥- ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីថា ខ្លួនសង្ស័យលើជនជាប់ចោទជាអ្នកលួចគោខ្លួន តែមិនបានបង្ហាញអ្វីច្បាស់លាស់ឡើយ, ឯសាក្សីក៏គ្មានបានបង្ហាញភស្តុតាងអ្វីច្បាស់លាស់ ដែលអាចឲ្យសន្និដ្ឋានបានថា ជនជាប់ចោទពិតជាអ្នកធ្វើសកម្មភាពលួចគោជនរងគ្រោះមែនដែរទេ។

៦- គ្មានភស្តុតាងបញ្ជាក់ពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] ផល ពីបទ លួចដោយមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិតាកុល ឃុំស្នាយអញ្ជិត ស្រុកជុំគីរី ខេត្តកំពត មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ឡើយ គួរឲ្យរួចផុតពីបទចោទ។

៧- សាលក្រមព្រហ្មទណ្ឌលេខ ៤៣ ឃ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកំពត សម្រេចមានលក្ខណៈខុសឆ្គង គួរបដិសេធចោល ហើយសម្រេចឡើងវិញ ដូចយល់ឃើញខាងលើ។

# ហេតុដូច្នេះ
# វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៦៧ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០១១ របស់ឈ្មោះ វ៉ា ផល ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមច្បាប់។

២- បដិសេធសាលក្រមព្រហ្មទណ្ឌលេខ ៤៣ ឃ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកំពត ចោលជាអសារបង់។

៣- ឲ្យឈ្មោះ [redacted] ផល រួចផុតពីបទចោទប្រកាន់ ពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិតាគុល ឃុំស្នាយអញ្ជិត ស្រុកជុំគីរី ខេត្តកំពត កាលពីថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៩ បទល្មើសមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៤- បង្គាប់ឲ្យដោះលែងឈ្មោះ [redacted] ផល ចេញពីពន្ធនាគារឲ្យមានសេរីភាពវិញជាបន្ទាន់ បើឈ្មោះនេះពុំត្រូវបានឃុំខ្លួនពីបទអ្វីផ្សេងទៀតទេ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១៣ ប្រកាសជាសាធារណៈនៅថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១៣ ចំពោះមុខឈ្មោះ [redacted] ផល និងមេធាវីការពារជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវសាទុក្ខ និងតវ៉ាតាមកំណត់ច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា: [redacted] |

---

បានឃើញ
**ប្រធានសាលាឧទ្ធរណ៍**

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី 04 ខែ 6 ឆ្នាំ ២០១៤
**ក្រឡាបញ្ជី**